# អភិណ្ហប្បច្ចវេក្ខណធម៌

វត្តនិគ្រោធវ័ន "គល់ទទឹង"

រៀបរៀងដោយ
ខ្ញុំព្រះករុណាអាត្មាភាព
មុនីកោសល្យ **នៅ~ហៃឡុង**

ព.ស ២៥៥២
**ចែកជាធម្មទាន**

៥០០០ឆ្នាំ

WWW.5000-YEARS.ORG



ឯកសារនេះបាន ទាញចេញពី គេហទំព័រ
www.5000-years.org

*មានបំណងនឹងទុកទំព័រនេះឲ្យទំនេរ*

# អារម្ភកថា

សៀវភៅនេះ កើតឡើងដោយអាស្រ័យហេតុដូចមានខាងក្រោមនេះ ៖

១-ថ្ងៃ ១៥ កើត ខែ ជេស ឆ្នាំ វក ឆស័ក ព.ស. ២៥៤៨ ជាលើកទី ១ ខ្ញុំមានសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា បានថតចម្លងសៀវភៅឈ្មោះ ទសបារមីកថារបស់ព្រះឧត្តមមុនី អ៊ុម-ស៊ូ អធិបតីរងក្រុមជំនុំព្រះត្រៃបិដក បានសម្រេចជា ធម្មទានរួចម្តងហើយ ។

ខែស្រាពណ៍ ឆ្នាំ វក ឆស័ក ព.ស. ២៥៤៨ ជាលើកទី ២ ខ្ញុំបានប្រមូលឯកសារ លំនាំ អត្ថបទរឿង ចរិយាបិដក និងប្រភេទនៃទុក្ករកិរិយាពីក្នុងគម្ពីរព្រះត្រៃ បិដកលេខ ៧៧ និងបិដកលេខ ២២ យកមកថត ចម្លងរៀបរៀងជា សៀវភៅឈ្មោះ បារមីកថា ពុទ្ធាបទាន បានសម្រេចជាធម្មទានរួចហើយ ។

ខែផល្គុន ឆ្នាំ វក ឆស័ក ព.ស. ២៥៤៨ ជាលើកទី ៣ ខ្ញុំបានប្រមូលឯក សារ អត្ថបទធម៌ ស្ថាន ៥ យ៉ាង ពីក្នុងគម្ពីរព្រះត្រៃបិដក លេខ ៤៤ យកមក ថតចម្លងរៀបរៀងជាសៀវភៅ ឈ្មោះ អភិណ្ហប្បច្ចវេក្ខណធម៌ បាន សម្រេចជាធម្មទានរួចម្តងហើយ ។

២- ដោយខ្ញុំយល់ឃើញថា សៀវភៅទាំង ៣ នេះមាន អក្សរ តូចផង និងមិនសូវច្បាស់ថែមទៀត លំបាកដល់ចាស់ ៗ គាត់មើល ខ្ញុំក៏បាន

សម្រេចចិត្តយកសៀវភៅទាំង ៣ នេះ ឱ្យកូនខ្ញុំ ឈ្មោះ **នៅ-ពីឡុត** សរសេរជាថ្មី លុះសរសេររួចស្រេចហើយ ខ្ញុំក៏យកទៅប្រគេនព្រះគ្រូ **ឥម្ពីរត្ថេរោឃី-ទិត** ព្រះវិនយធរគណ ស្រុកកៀនស្វាយ ខេត្តកណ្ដាល និងលោកម្ចាស់គ្រូ **មេត្តាបាលោ ទីម-សឿត** ចៅអធិការវត្តនិគ្រោធវ័ន ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ព្រមទាំងព្រះថេរៈជាច្រើនអង្គ ដែលជាអ្នកឈ្លាសវៃក្នុងព្រះធម៌ សូមឱ្យលោកជួយពិនិត្យផ្ទៀងផ្ទាត់ មើលថែមទៀត លោកក៏យកចិត្តទុកដាក់ជួយពិនិត្យឱ្យ ឃើញថាត្រឹមត្រូវតាមច្បាប់ដើម ឥតមានទាស់ខុសអ្វីឡើយ ទើបខ្ញុំយកឯកសារនេះ ទៅចាត់ចែងបោះពុម្ពចែកជាធម្មទានតាមសេចក្ដីជ្រះថ្លា ។

ដោយអំណាចនៃបុណ្យកុសល ដែលកើតអំពីធម្មទាននេះ សូមជាបច្ច័យបានប្រកបដោយសតិ បញ្ញា ស្មារតី ជាសម្មាទិដ្ឋិ បានសុខក្នុងលោកទាំងពីរ រហូតដល់អវសានជាតិ សូមកើតមានដល់លោកអ្នកមានគុណមានមាតា បិតាជាដើមផង ដល់លោកអ្នកដែលមានឧបការៈក្នុងការងារធម្មទានផង ព្រមទាំងសព្វសត្វទាំងអស់គ្រប់រូប ។

ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន "គល់ទទឹង"

ថ្ងៃ ១២ រោច ខែពិសាខ ឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៥៥២

ខ្ញុំព្រះករុណា អាត្មាភាព **មុនីកោសល្យ នៅ-ហៃឡុន**

# បញ្ជីមាតិកា

**មាតិកាអភិណ្ហប្បច្ចវេក្ខណធម៌** ទំព័រ

អារម្ភកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ក

បញ្ជីមាតិកា .. ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... គ

អ្នកមានឧបការៈ ... ... ... ... ... ... ... ... ... ... ... ... ... ... ឃ

អភិណ្ហប្បច្ចវេក្ខណធម៌

ស្ថាន ៥ យ៉ាង គួរពិចារណារឿយ ៗ ... ... ... ... ... ... ... ... ១

ពិចារណាដើម្បីលះបង់អកុសលធម៌ ៥ យ៉ាង . ... ... ... ... ... ៤

ការពិចារណារបស់ព្រះអរិយសាវ័ក.. ... ... ... ... ... ... ... ... ៨

អដ្ឋកថា អភិណ្ហប្បច្ចវេក្ខណធម៌.. ... ... ... ... ... ... ... ... ... ១៣

អធិប្បាយសេចក្ដីស្រវឹង ២៧ ប្រការ ... ... ... ... ... ... ... ... ១៧

អធិប្បាយពាក្យថា ឧបធិ... ... ... ... ... ... ... ... ... ... ... ... ២៩

អភិណ្ហប្បច្ចវេក្ខណធម៌... ... ... ... ... ... ... ... ... ...... ... ... ៣៣

ចប់ មាតិកាអភិណ្ហប្បច្ចវេក្ខណធម៌

## អ្នកមានឧបការៈ

១- លោកម្ចាស់ គូ-សុភាព

២- លោកម្ចាស់ អ៊ិន-សំអឿន

៣- លោកម្ចាស់ ភួង-សុវណ្ណ

៤- លោកម្ចាស់ ឆាយ-កន

៥- លោកម្ចាស់ គង់-សុមិត្ត

៦- លោកម្ចាស់ សូរ-ស៊ីម

៧- សាមណេរ ស៊ឹម-ស៊ីសាមុត

៨- យុវសិស្ស នៅ-ពីឡុត

៩- ឧបាសិកា ហុង-ចេង

# អភិណ្ហប្បច្ចវេក្ខណធម៌

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ។

## ស្ថាន ៥ យ៉ាង គួរពិចារណារឿយ ៗ

**បញ្ចិមានិ ភិក្ខវេ ឋានានិ អភិណ្ហំ បច្ចវេក្ខិតព្វានិ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។**

ម្នាលភិក្ខុទាំងឡាយស្ថាន ៥ យ៉ាងនេះ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយ ៗ ។

**កតមានិ បញ្ច ។** ស្ថាន ៥ យ៉ាងតើដូចម្តេច ។

**ជរាធម្មោម្ហិ ជរំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។**

ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា

អាត្មាអញមានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ១ ។

**ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ២**

ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ១ ។

**មរណធម្មោម្ហិ មរណំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ២**

ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ ១ ។

**សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន**

**វា គហដ្ឋេន វា បព្វជិតេន វា ។**

ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញតែងមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ១ ។

**កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។**

ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណាទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលនូវផលនៃកម្មនោះ ១ ។

# ប្រយោជន៍នៃការពិចារណា ៥ យ៉ាង

ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានជរាជាធម្មតា មិនកន្លងជរាទៅបាន តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹងក្នុងវ័យដ៏ចម្រើន ដែលជាហេតុនាំឱ្យពួកសត្វប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលនោះពិចារណាស្ថាននោះរឿយៗហើយ ក៏លះបង់យោព្វនមទៈ(សេចក្តីស្រវឹងក្នុងវ័យដ៏ចម្រើន) ដោយសព្វគ្រប់ ឬពុំនោះសោត ក៏គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានជរា ជាធម្មតាមិនកន្លងជរាទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹងក្នុងភាព នៃខ្លួនជាអ្នកមិនមានរោគ ដែលជាហេតុនាំឱ្យពួកសត្វ ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយៗហើយ គង់លះបង់ អារោគ្យមទៈ (សេចក្តីស្រវឹងក្នុងភាវៈនៃខ្លួនមិនមានរោគ) ដោយសព្វ គ្រប់ ឬពុំនោះសោត គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន ព្រោះអាស្រ័យ អំណាចប្រយោជន៍នេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរ ពិចារណារឿយៗថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លង សេចក្តីស្លាប់ទៅបាន តើព្រោះអាស្រ័យអំណាចប្រយោជន៍ ដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្តីស្រវឹងក្នុងជីវិត ដែលជាហេតុនាំឱ្យពួកសត្វ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលនោះ ពិចារណា នូវស្ថាននោះរឿយៗហើយ គង់លះបង់ជីវិតមទៈ (សេចក្តីស្រវឹងក្នុង

ជីវិត) ដោយសព្វគ្រប់ឬពុំនោះសោត គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញតែងមានសេចក្តីព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួងតើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានតម្រេកក្រៃលែងក្នុងសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្ត ដែលជាហេតុនាំឱ្យសត្វប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយៗហើយ គង់លះបង់ឆន្ទរាគ (តម្រេកក្រៃលែង) ក្នុងសត្វ និងសង្ខារដោយសព្វគ្រប់ ឬពុំនោះសោត គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វនិង

សង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ។ កាលបើបុគ្គលនោះ ពិចារណានូវស្ថាននោះរឿយៗហើយ គង់លះបង់ទុច្ចរិតដោយសព្វគ្រប់ ឬពុំនោះសោត ក៏គង់ស្រាលស្តើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

# ការពិចារណារបស់ព្រះអរិយសាវ័ក

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនោះ តែងពិចារណាថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានជរាជាធម្មតា មិនកន្លងជរាទៅបាន ទោះបីពួកសត្វដែលមានការរង្គាត់មករង្គាត់ទៅ ច្យុត និងកើតអម្បាលម៉ាន ពួកសត្វទាំងអស់ ក៏តែងមានជរាជាធម្មតា មិនកន្លងជរាទៅបានដែរ កាលបើអរិយសាវ័កនោះ ពិចារណានូវស្ថាននោះរឿយៗហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវ័កនោះ រមែងសេព ចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវ័កនោះ សេព ចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយ-ក្កិលេសទាំងឡាយក៏វិនាសទៅ ។

(អរិយសាវ័កនោះ ពិចារណា) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន ទោះពួកសត្វដែលមានការរង្គាត់មករង្គាត់ទៅ ច្យុត កើត អម្បាលម៉ាន ពួកសត្វទាំងអស់ក៏មាន ព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានដែរ កាល

បើអរិយសាវ័កនោះ ពិចារណានូវស្ថាននោះរឿយៗហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវ័កនោះ សេព ចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវ័កនោះ សេពចម្រើន ធ្វើរឿយៗ នូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយក៏វិនាសទៅ ។

(អរិយសាវ័កនោះ ពិចារណា) ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដីស្លាប់ទៅបានទោះពួកសត្វដែលមានការរង្គាត់មក រង្គាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ ក៏មានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដីស្លាប់ទៅបានដែរ កាលបើអរិយសាវ័កនោះ ពិចារណានូវស្ថាននោះរឿយៗហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវ័កនោះ រមែងសេព ចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវ័កនោះ សេព ចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយក៏វិនាសទៅ ។

(អរិយសាវ័កនោះ ពិចារណា)ថា មិនមែនតែអាត្មាអញម្នាក់ឯងទេ ដែលមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង ទោះពួកសត្វដែលមានការរង្គាត់មក រង្គាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ មានសេចក្តីព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួងដែរ កាលបើអរិយសាវ័កនោះ ពិចារណានូវស្ថាននោះរឿយៗហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ កាលបើអរិយសាវ័កនោះ សេពចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយក៏វិនាសទៅ ។

(អរិយសាវ័កនោះ ពិចារណា)ថា មិនមែនតែអាត្មាអញតែម្នាក់ឯងទេ ដែលមានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ ទោះពួកសត្វដែលមានការរង្គាត់មក រង្គាត់ទៅ ច្យុត កើតអម្បាលម៉ាន ពួកសត្វទាំងអស់ ក៏មានកម្មជារបស់ខ្លួន មានកម្មជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក ពួកសត្វ

នឹងធ្វើកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះដែរ កាលបើអរិយសាវ័កនោះ ពិចារណានូវស្ថាននោះរឿយៗហើយ លោកុត្តរមគ្គក៏កើតឡើងព្រម ។ អរិយសាវ័កនោះរមែងសេព ចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះ ។ កាលបើអរិយសាវ័កនោះ សេព ចម្រើន ធ្វើរឿយៗនូវលោកុត្តរមគ្គនោះហើយ សញ្ញោជនៈទាំងឡាយ ក៏រមែងសាបសូន្យទៅ អនុសយក្កិលេសទាំងឡាយក៏វិនាសទៅ ។

**ព្យាធិធម្មា ជរាធម្មា អថោ មរណធម្មិនោ**
**យថា ធម្មា តថា សន្តា ជិគុច្ឆន្តិ បុថុជ្ជនា ៕**
**អហញ្ចេតំ ជិគុច្ឆេយ្យំ ឯវំ ធម្មេសុ បាណិសុ**
**ន មេតំ បដិរូបស្ស មម ឯវំ វិហារិនោ ៕**
**សោហំ ឯវំ វិហរន្តោ ញត្វា ធម្មំ និរុបធឹ**
**អារោគ្យេ ច យោព្វនស្មឹ ជីវិតស្មិញ្ច យោ មទោ**
**សព្វេ មទេ អភិភោស្មិ នេក្ខម្មំ ទដ្ឋុ ខេមតោ ៕**
**តស្ស មេ អហុ ឧស្សាហោ និព្វានំ អភិបស្សតោ**

**នាហំ ភគ្គោ ឯតរហិ កាមានិ បដិសេវិតុំ**
**អនិវត្តិ ភវិស្សាមិ ព្រហ្មចេរបរាយនោតិ ។**

ធម៌ទាំងឡាយ គឺព្យាធិធម៌ ជរាធម៌និងមរណធម៌ មាននៅយ៉ាងណា ពួកបុថុជ្ជន ជាសប្បុរសរមែងស្អប់ខ្ពើមយ៉ាងនោះ ។ កាលបើពួកសត្វមានសភាវៈយ៉ាងនេះហើយ តថាគតក៏គួរធុញទ្រាន់នឹងសភាវៈនុ៎ះដែរ ហេតុនុ៎ះមិនមានដល់តថាគត មានសភាពដ៏សមគួរ មានវិហារធម៌យ៉ាងនេះ តថាគតនោះ កាលបើនៅយ៉ាងនេះ ក៏ដឹងនូវធម៌ដែលប្រាសចាកឧបធិ បានឃើញបព្វជ្ជាថា ជាការក្សេមគ្របសង្កត់នូវសេចក្តីស្រវឹងទាំងពួង គឺស្រវឹងក្នុងភាវៈនៃខ្លួនជាបុគ្គលមិនមានរោគ ក្នុងវ័យ ក្នុងជីវិតបាន។ សេចក្តីព្យាយាមក៏កើតមានដល់តថាគតនោះ កាលដែលឃើញច្បាស់នូវព្រះនិព្វាន តថាគតមិនគួរដើម្បីសេពកាមទាំងឡាយបានវិញ ក្នុងកាលឥឡូវនេះទេ តថាគតនឹងជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ តទៅមិនបានត្រឡប់វិញឡើយ ។

(បិដកភាគ ៤៤ ទំព័រ ១៤៦)

# អដ្ឋកថា អភិណ្ហប្បច្ចវេក្ខណធម៌

គប្បីជ្រាបវិនិច្ឆ័យក្នុងឋានសូត្រទី ៧ ដូចតទៅនេះ :

បទថា **ជរាធម្មោម្ហិ** ប្រែថា **អាត្មាអញមានជរាជាធម្មតា** គឺ អាត្មាអញជាអ្នកមានសេចក្ដីចាស់ជាធម្មតា ។

បទថា **ជរំ អនតីតោ** ប្រែថា **មិនកន្លងជរាទៅបានឡើយ** សេចក្ដីថា អាត្មាអញមិនកន្លងផុតសេចក្ដីចាស់ទៅបាន រមែងត្រាច់ទៅ ក្នុងសេចក្ដីចាស់មែនពិត ។ សូម្បីក្នុងបទទាំងឡាយដ៏សេស ក៏មានន័យដូច្នេះដូចគ្នា ។

ក្នុងបទទាំងឡាយថា **កម្មស្សកោ** ប្រែថា **អាត្មាអញមានកម្មជារបស់ខ្លួនជាដើម កម្មជារបស់អាត្មាអញ** គឺ ជារបស់មាននៅសំរាប់ជារបស់ខ្លួនអញ ព្រោះដូច្នោះ អាត្មាអញទើបឈ្មោះថា មានកម្មជារបស់ខ្លួន ។

បទថា **កម្មទាយាទោ** ប្រែថា **មានកម្មជាមតិក** គឺ អាត្មាអញជាទាយាទរបស់កម្ម អធិប្បាយថា កម្មជាមតិក គឺជាសម្បត្តិរបស់អាត្មាអញ កម្មជាកំណើតគឺ ជាហេតុកើតរបស់អាត្មា

អញ ព្រោះហេតុដូច្នោះ អាត្មាអញទើបឈ្មោះថា មានកម្មជាកំណើត ។ កម្មជាផៅពង្សរបស់អាត្មាអញ ព្រោះហេតុដូច្នោះ អាត្មាអញទើបឈ្មោះថា មានកម្មជាផៅពង្ស ។ អធិប្បាយថាមានកម្មជាញាតិ ។ កម្មជាទីអាស្រ័យ គឺជាទីពឹងរបស់អាត្មាអញ ព្រោះហេតុដូច្នោះ អាត្មាអញទើបឈ្មោះថា មានកម្មជាទីអាស្រ័យ ។

បទថា **តស្ស ទាយាទោ ភវិស្សាមិ** ប្រែថា **នឹងជាអ្នកទទួលនូវផលនៃកម្មនោះ** គឺ អាត្មាអញជាទាយាទរបស់កម្មនោះ អធិប្បាយថា យើងនឹងជាអ្នកទទួលផល ដែលកម្មនោះឱ្យ ។

បទថា **យោព្វនមទោ** ប្រែថា **មានសេចក្តីស្រវឹងក្នុងវ័យដ៏ចម្រើន** បានដល់ សេចក្តីស្រវឹងកើតឡើង ប្រារព្ធនូវភាពជាកំលោះក្រមុំ ។

សូម្បីក្នុងបទទាំងឡាយដ៏សេសក៏មានន័យដូចគ្នា ។

បទថា **មគ្គោ សញ្ជាយតិ** ប្រែថា **មគ្គក៏កើតឡើងព្រម** បានដល់ លោកុត្តរមគ្គ រមែងកើតឡើងព្រម ។

បទថា **សំយោជនានិ បហីយន្តិ** ប្រែថា **សញ្ញោជនទាំងឡាយ ក៏រមែងសាបសូន្យទៅ** សេចក្តីថា សញ្ញោជនៈ ១០ ប្រការ

លោករមែងលះបានដោយប្រការទាំងពួង ។

បទថា **អនុសយា ព្យន្តី ហោន្តិ** ប្រែថា **អនុសយក្កិលេសទាំងឡាយ ក៏វិនាសទៅ** សេចក្ដីថា អនុស័យ ៧ ប្រការដល់ទីបំផុតហើយ គឺមានផ្លូវជុំវិញៗកាត់ដាច់ហើយ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់វិបស្សនាក្នុងឋានទាំង ៥ ក្នុងកាលមុនទុកហើយ ដោយប្រការដូច្នេះ ត្រាស់លោកុត្តរមគ្គក្នុងឋាន ទាំង ៥ នេះ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សរុបដោយគាថាទាំងឡាយទើបត្រាស់ថា **ព្យាធិធម្មា** ជាដើម ។

បណ្ដាបទទាំងនោះបទថា **ញត្វា ធម្មំ និរូបធឹ** ប្រែថា **ក៏ដឹងនូវធម៌ដែលប្រាសចាកឧបធិ** សេចក្ដីថា ដឹងធម៌គឺព្រះអរហត្ត ដែលប្រាសចាកឧបធិហើយ ។

បទថា **សព្វេ មទេ អភិភោស្មិ** ប្រែថា **គ្របសង្កត់នូវសេចក្ដីស្រវឹងទាំងពួង** សេចក្ដីថា តថាគតគ្របសង្កត់សេចក្ដីស្រវឹងសូម្បីទាំង ៣ យ៉ាងនេះបានទាំងអស់ អធិប្បាយថា តថាគតកន្លងចេញហើយឋិតនៅ ។

បទថា **នេក្ខម្មំ ទដ្ឋុ ខេមតោ** ប្រែថា **បានឃើញបព្វជ្ជាថាជាការក្សេម** សេចក្ដីថា ឃើញការបព្វជ្ជា ដោយសេចក្ដីថាជារបស់ក្សេម ។

បទថា **តស្ស មេ អហុ ឧស្សាហោ និព្វានំ អភិបស្សតោ** ប្រែថា **សេចក្ដីព្យាយាមក៏កើតមានដល់តថាគតនោះកាលដែលឃើញច្បាស់នូវព្រះនិព្វាន** នោះ សេចក្ដីថា សំរាប់តថាគតអ្នកឃើញច្បាស់នូវព្រះនិព្វាន បានមានសេចក្ដីព្យាយាមហើយ ។

បទថា **អនិវត្តិ ភវិស្សាមិ** ប្រែថា **តថាគតមិនគួរ** សេចក្ដីថា តថាគតនឹងជាអ្នកមិនត្រឡប់ទៅចាកការបព្វជ្ជា និងមិនត្រឡប់ទៅចាកការប្រព្រឹត្តព្រហ្មចរិយ និងមិនត្រឡប់ទៅចាកព្រះសព្វញ្ញុត-ញ្ញាណ ។

បទថា **ព្រហ្មចរិយបរាយណ** ប្រែថា **នឹងជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌តទៅ** នោះ គឺ នឹងជាអ្នកមានមគ្គព្រហ្មចរិយៈ ជាខាងមុខ ។ ដោយបទនេះ ព្រះមានព្រះភាគត្រាស់ដល់មគ្គ មានអង្គ ៨ ដែលជាលោកុត្តរទុកដោយប្រការដូច្នេះ ។

## អធិប្បាយសេចក្តីស្រវឹង ២៧ ប្រការ

បណ្តាធម៌ទាំងនោះ សេចក្តីស្រវឹងតើដូចម្តេច ។ ការស្រវឹង អាការស្រវឹង ភាពនៃសេចក្តីស្រវឹង ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្ត ដូចជាទង់ណា នេះហៅថា សេចក្តីស្រវឹង ។

១ អំពីការស្រវឹងក្នុងភាពជាអ្នកមិនមានរោគ ក្នុងបណ្តាសេចក្តីស្រវឹងទាំងឡាយ មានសេចក្តីស្រវឹងក្នុងភាពជាអ្នកមិនមានរោគជាដើម មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា យើងមិនមានរោគជាដើម ជនទាំងឡាយដទៃ (វៀរយើង) មានរោគច្រើន ក៏ឈ្មោះថា ព្យាធិ សូម្បីត្រឹមតែដំណួចពិសរបស់យើងក៏មិនមាន ឈ្មោះថា អារោគ្យមទោ ស្រវឹងក្នុងភាពមិនមានរោគ ។

២ អំពីការស្រវឹងក្នុងជាតិ មានះដែលកើតឡើង ព្រោះអាស្រ័យជាតិ ដែលជាហេតុនាំឱ្យដល់សេចក្តីស្រវឹង ព្រោះថា ជាតិមទោ ស្រវឹងព្រោះអាស្រ័យជាតិ ជាតិមទោនេះ រមែងកើតឡើងដល់វណ្ណៈទាំង ៤ គឺក្សត្រ ១ ព្រាហ្មណ៍ ១ វេស្ស (ពួកឈ្មួញ) ១ សូទ្រ

(អ្នកបម្រើ) ១ ។ ពិតមែន សូម្បីក្សត្រជាអ្នកដល់ព្រមដោយជាតិ គឺកំណើតខ្ពង់ខ្ពស់ រមែងតម្កើងនូវមានះ (ប្រកាន់ខ្លួន)ថា ពួកក្សត្រដទៃដូចជាអាត្មាអញមិនមាន ពួកក្សត្រទាំងអស់នោះ គ្រាន់តែជាការតែងតាំងឱ្យឡើងជាក្សត្រប៉ុណ្ណោះ ។ ចំណែកអាត្មាអញវិញ គឺជាក្សត្រជាប់តពីវង្សានុវង្សមកម្លេះ ។

សូម្បីវណ្ណៈ ៣ ទៀត ក៏មានន័យដូចគ្នាយ៉ាងនេះឯង ។ ទាំងអស់នេះ លោកហៅថា ជាតិមទោ ស្រវឹងព្រោះអាស្រ័យជាតិ ។

៣ អំពីការស្រវឹង ព្រោះអាស្រ័យគោត្រ មានះដែលកើតឡើង ព្រោះអាស្រ័យគោត្រ ដែលជាហេតុនាំឱ្យដល់នូវសេចក្ដីស្រវឹង ព្រោះថា គោត្តមទោ ស្រវឹងព្រោះអាស្រ័យគោត្រ ។ ក៏គោត្តមទោនេះរមែងកើតឡើងក្នុងវណ្ណៈទាំង ៤ គឺ ក្សត្រជាដើម ។ ពិតមែន សូម្បីបានកើត ក្នុងវង្សត្រកូលជាក្សត្រហើយ ក៏នៅមានសេចក្ដីប្រកាន់លើកតម្កើងខ្លួន ព្រោះអាស្រ័យគោត្រជាហេតុដែរ រមែងប្រកាន់ថា យើងជាកោណ្ឌញ្ញគោត្ត យើងជាអាទិច្ចគោត្តជាដើម ។ សូម្បីពួកព្រាហ្មណ៍ក៏ដូចគ្នា រមែងប្រកាន់ថា យើងជាកស្សបគោត្ត យើងជាភារទ្វាជគោត្តជាដើម ។ ចំណែកពួកវេស្សនិងសូទ្រក៏ដូចគ្នា

រមែងប្រកាន់ខ្លួនព្រោះអាស្រ័យ គោត្តរបស់គេរៀងៗខ្លួនដែរ ។ ចំពោះគោត្តមទោនេះ យើងអាចសំគាល់ដឹងបាន មិនថា ប្រទេសណា ឬនិគមជនបទណាក៏ដោយ បើនៅក្នុងនិគមជនបទនោះៗ មានពូជពង្សវង្សត្រកូលណាមួយដែលគេសន្មតិថា ជាត្រកូលខ្ពង់ខ្ពស់ ជាអ្នកមានមុខមាត់ក្នុងនិគមនោះៗ បើបុគ្គលនៅក្នុងត្រកូលនោះ ឬជាប់ខ្សែស្រឡាយនៃត្រកូលនោះៗ ហើយលើកតម្កើងខ្លួនដោយមានមានះថា យើងមានត្រកូលយ៉ាងនេះ យើងមានត្រកូលយ៉ាងនោះ តាមដែលគេសន្មតិនោះ ឈ្មោះថា គោត្តមទោ ស្រវឹងព្រោះអាស្រ័យគោត្រ ។

៤ អំពីការស្រវឹងក្នុងភាពជាកំលោះក្រមុំ មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា យើងទើបជាកំលោះ-ក្រមុំ អត្តភាពរបស់សត្វទាំងឡាយដ៏សេស(វៀរយើង) ដូចជាដើមឈើតាំងនៅក្នុងមាត់ជ្រោះ ចំណែកយើងតាំងនៅក្នុងបឋមវ័យ ឈ្មោះថា យោព្វនមទោ ស្រវឹងក្នុងអត្តភាពជាកម្លោះក្រមុំ ។

៥ អំពីការស្រវឹងក្នុងជីវិត មានះដែលកើតឡើងដោយអំណាចនៃសេចក្ដីស្រវឹងថា យើងបានរស់នៅយូរហើយ យើងបានរស់

នៅយូរ យើងនឹងបានរស់នៅយូរ យើងរស់នៅជាសុខហើយ យើងរស់នៅជាសុខ យើងនឹងរស់នៅជាសុខ ឈ្មោះថា ជីវិតមទោ ស្រវឹងក្នុងជីវិត ។

៦ អំពីការស្រវឹងក្នុងលាភ មាន៖ដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា យើងមានលាភច្រើន សត្វទាំងឡាយដទៃដ៏សេស (ក្រៅអំពីយើង) មានលាភតិច ក៏លាភទាំងឡាយរបស់យើងមានប្រមាណរាប់មិនបាន ឈ្មោះថា លាភមទោ ស្រវឹងក្នុងលាភ ។

៧ អំពីការស្រវឹងក្នុងសក្ការៈ មាន៖ដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេសបានបច្ច័យណាៗយើងប៉ុណ្ណោះ ដែលបានបច្ច័យមានចីវរជាដើមដ៏ប្រណីត ដែលគេធ្វើល្អហើយ ឈ្មោះថា សក្ការមទោ ស្រវឹងក្នុងសក្ការៈ ។

៨ អំពីការស្រវឹងក្នុងការគោរព មាន៖ដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា ជនទាំងឡាយ ដើរតាមក្រោយភិក្ខុទាំងឡាយ រមែងមិនសំពះភិក្ខុនោះ ដោយគិតថា អ្នកនេះជាសមណៈដូច្នេះខ្លះ តែពួកគេទាំងនោះ ឃើញយើងហើយ រមែងសំពះតែម្តង

ធ្វើសេចក្តីគោរពយើង ប្រៀបដូចជាឆត្រ ដែលដោតជាប់នៅក្នុងថ្ន រមែងធ្វើសេចក្តីសំគាល់យើងថា ជាអ្នកចូលទៅរកបានសំឡេងទះដៃព្រម១គ្នា ដូចគំនរភ្លើងដូច្នោះ ឈ្មោះថា គរុការមទោ ស្រវឹងក្នុងការធ្វើសេចក្តីគោរព ។

៩ អំពីការស្រវឹងក្នុងភាពជាមេដឹកនាំ មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា បញ្ហាដែលកើតឡើងហើយ រមែងកាត់សេចក្តីសម្រេចបាន ដោយមាត់របស់យើងប៉ុណ្ណោះ សូម្បីកាលទៅភិក្ខាចារ ក៏ធ្វើយើងប៉ុណ្ណោះឱ្យនៅខាងមុខហើយ ទើបហែហមទៅតាមក្រោយ ឈ្មោះថា បុរេក្ខាមទោ ស្រវឹងក្នុងភាពជាមេដឹកនាំ ។

១០ អំពីការស្រវឹងក្នុងបរិវារ មានះដែលកើតឡើងដល់អ្នកគ្រប់គ្រងផ្ទះ អ្នកមានបរិវារច្រើន ដោយអំណាចនៃសេចក្តីស្រវឹងថា បុរសមួយរយអ្នកខ្លះ មួយពាន់អ្នកខ្លះ រមែងនៅជុំវិញយើង ចំណែកមានះដែលកើតឡើង ដល់អ្នកមិនគ្រប់គ្រងផ្ទះ(គឺសមណៈ) ដោយអំណាចនៃសេចក្តីស្រវឹងថា សមណៈមួយរយនាក់ខ្លះ មួយពាន់នាក់ខ្លះ នៅជុំវិញយើង សមណៈដ៏សេសមានបរិវារតិច យើងមានបរិវារច្រើន ឈ្មោះថា បរិវារមទោ ស្រវឹងក្នុងបរិវារ ។

១១ អំពីការស្រវឹងក្នុងភោគសម្បត្តិ ក៏ភោគសម្បត្តិលោកកាន់យកដោយលាភស័ព្ទនេះឯង ក៏ពិតមែន ប៉ុន្តែ លោកកាន់យកគំនរនៃភោគៈដែលតាំងទុកក្នុងទីនេះទៀត ព្រោះហេតុដូច្នោះ មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដែលក្រៅអំពីយើងហើយរមែងមិនបាន សូម្បីតែការប្រើប្រាស់របស់ខ្លួន, ចំណែកយើងមានទ្រព្យរក្សាទុក (កំណប់ទ្រព្យ) រាប់មិនបាន ឈ្មោះថា ភោគមទោ ស្រវឹងក្នុងភោគសម្បត្តិ ។

១២ អំពីការស្រវឹងក្នុងពណ៌សម្បុរ ពាក្យថា **វណ្ណំ បដិច្ច** បានដល់ អាស្រ័យពណ៌សម្បុរគឺ សម្បុរនៃសរីរៈខ្លះ សម្បុរគឺគុណសេចក្តីល្អខ្លះ ។ មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស(ក្រៅអំពីយើង) មានពណ៌សម្បុរមិនល្អ មានរូបមិនស្អាត ចំណែកយើងមានរូបស្អាតគួរជ្រះថ្លា សត្វទាំងឡាយដ៏សេស មានគុណគឺសេចក្តីល្អ មិនជាទីសរសើរ ចំណែកយើងមានកិត្តិសព្ទផ្សាយទៅក្នុងទេវតានិងមនុស្សទាំងឡាយថា សូម្បីព្រោះហេតុនេះៗ... យើងជាព្រះថេរៈ យើងជាពហុស្សូត សូម្បីព្រោះហេតុនេះ

យើងជាអ្នកមានសីលសម្បូរ ព្រោះហេតុនេះ យើងជាអ្នកប្រកបដោយគុណនៃធុតង្គជាដើម ឈ្មោះថា វណ្ណមទោ ស្រវឹងក្នុងពណ៌សម្បុរ ។

១៣ អំពីការស្រវឹងក្នុងការសិក្សា មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេសមានការសិក្សាតិច ចំណែកយើងមានការសិក្សាច្រើន ឈ្មោះថា សុត្តមទោ ស្រវឹងក្នុងការសិក្សា ។

១៤ អំពីការស្រវឹងក្នុងបដិភាណ មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស (វៀរយើងហើយ) មិនមាន បដិភាណ(ភាពឆ្លៀវឆ្លាស) ចំណែកយើងមានបដិភាណប្រមាណមិនបាន ឈ្មោះថា បដិភាណមទោ ស្រវឹងក្នុងភាពឆ្លៀវឆ្លាស ។

១៥ អំពីការស្រវឹងក្នុងរត្តញ្ញូ មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា យើងជាអ្នកដឹងរាត្រីយូរ យើងដឹងត្រកូលរបស់ព្រះពុទ្ធអង្គនោះ រមែងដឹងព្រះពុទ្ធអង្គនោះ ដឹងត្រកូលនៃជនបទនោះ ដឹងត្រកូលនៃស្រុកនោះ ដឹងនូវការកំណត់ទាំងពេល

យប់និងពេលថ្ងៃ ដឹងនូវការប្រកបឬក្សនិងការទាយ ឈ្មោះថា វត្តញ្ញូមទោ ស្រវឹងក្នុងវត្តញ្ញូ ។

១៦ អំពីការស្រវឹងក្នុងការកាន់បិណ្ឌបាតជាវត្ត មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា ភិក្ខុទាំងឡាយកាន់បិណ្ឌបាត ជាវត្តត្រឹមតែបន្តិចបន្តួច ឯយើងកាន់បិណ្ឌបាតជាវត្ត តាំងតែពីបួសមក ឈ្មោះថា បិណ្ឌបាតិកមទោ ស្រវឹងក្នុងការកាន់បិណ្ឌបាតជាវត្ត ។

១៧ អំពីការស្រវឹងដោយមិនមានអ្នកណាមើលងាយ មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេសជាអ្នកត្រូវគេមើលងាយមើលថោក ឯយើងមិនមានអ្នកណាមើលងាយមើលថោកឡើយ ឈ្មោះថា អនវញ្ញាតមទោ ស្រវឹងដោយមិនមានអ្នកណាមើលងាយ ។

១៨ អំពីការស្រវឹងក្នុងឥរិយាបថ មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា ឥរិយាបថរបស់សត្វទាំងឡាយ មិនគួរជ្រះថ្លា ឯយើងគួរជ្រះថ្លា ឈ្មោះថា ឥរិយាបថមទោ ស្រវឹងក្នុង

ឥរិយាបថ ។

១៩ អំពីការស្រវឹងក្នុងឫទ្ធិ មានះដែលកើតឡើងដោយអំណាចនៃសេចក្ដីស្រវឹងថា សត្វទាំងឡាយដ៏សេស ដូចជាសត្វក្អែកបាក់ស្លាបហើរមិនរួច ចំណែកយើងមានឫទ្ធិច្រើន មានអានុភាពច្រើន ឬថា យើងនឹងធ្វើវត្ថុណាៗក៏សម្រេច ឈ្មោះថា ឥទ្ធិមទោ ស្រវឹងក្នុងឫទ្ធិ ។

២០ អំពីការស្រវឹងក្នុងយសសក្តិ យសលោកកាន់យកដោយបរិវារសព្ទក្នុងកាលមុននោះឯង តែក្នុងទីនេះលោកកាន់ភាពជាអ្នកស្រវឹងក្នុងឧបដ្ឋាកសេចក្ដីស្រវឹងនោះ បណ្ឌិតគប្បីសំដែងដោយបុគ្គលអ្នកគ្រប់គ្រងផ្ទះខ្លះ អ្នកមិនគ្រប់គ្រងផ្ទះខ្លះ ក៏បណ្ដាប្រជុំជន ១៨ ពួក អ្នកគ្រប់គ្រងផ្ទះមួយក្រុម ក៏មានប្រធាន ១ មានះដែលកើតឡើងដោយអំណាចនៃសេចក្ដីស្រវឹងថា យើងនឹងតែងតាំងមនុស្សជាអ្នកទំនុកបំរុងយើង យើងដើរទៅ សូម្បីអ្នកមិនគ្រប់គ្រងផ្ទះ (សមណៈ) ជាប្រធានគណៈ ក៏មានសេចក្ដីសំគាល់ខ្លួន ដោយអំណាចនៃសេចក្ដីស្រវឹងថា យើងជាប្រធានលើភិក្ខុទាំងឡាយ អ្នកប្រព្រឹត្ត

នៅក្នុងឱវាទរបស់យើងជាដើម ឈ្មោះថា យសមទោ ស្រវឹងក្នុងយសសក្តិ ។

២១ អំពីការស្រវឹងក្នុងសីល មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស (វៀរយើងហើយ) ជាអ្នកទ្រុស្តសីល ឯយើងជាអ្នកមានសីល ឈ្មោះថា សីលមទោ ស្រវឹងក្នុងសីល ។

២២ អំពីការស្រវឹងក្នុងសមាធិ មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស (វៀរយើងហើយ) មិនមានឯកគ្គតាចិត្ត(សមាធិ) ក្នុងកាលសូម្បីត្រឹមតែថាការផឹកទឹករបស់មាន់ ចំណែកយើងបានឧបចារឈានឬអប្បណាឈាន ឈ្មោះថា ឈានមទោ ស្រវឹងក្នុងសមាធិ ។

២៣ អំពីការស្រវឹងក្នុងសិប្បៈ មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស (ក្រៅពីយើង) មិនមាន តែយើងមានសិប្បៈ ឈ្មោះថា សិប្បមទោ ស្រវឹងក្នុងសិប្បៈ ។

២៤ អំពីការស្រវឹងក្នុងភាពជាអ្នកមានកំពស់ មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា សត្វទាំងឡាយដ៏សេស (វៀរយើងហើយ) មានរៀងកាយតឿ ចំណែកយើងមានរាងកាយខ្ពស់ ឈ្មោះថា អារោហមទោ ស្រវឹងព្រោះមានកំពស់ ។

២៥ អំពីការស្រវឹងក្នុងភាពជាអ្នកមានទំហំ មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា សត្វទាំងឡាយដ៏សេស (វៀរយើងហើយ) មានរាងកាយទាបពេក ខ្ពស់ពេក ឯយើងមានទ្រង់ទ្រាយសមល្មម ដូចដើមនិគ្រោធ (ដើមជ្រៃ) បរិណាហមទោ ស្រវឹង ព្រោះមានទំហំ ។

២៦ អំពីការស្រវឹងក្នុងភាពជាអ្នកមានទ្រង់ទ្រាយ មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា អាកប្បកិរិយារបស់សត្វ ទាំងឡាយដ៏សេស (វៀរយើងហើយ) មានរូបរាងប្លែកមិនគួរសរសើរ ឯយើងវិញមានរូបគួរពេញចិត្ត គួរជាទីជ្រះថ្លាឈ្មោះថាសណ្ឋានមទោ ស្រវឹងព្រោះមានទ្រង់ទ្រាយ ។

២៧ អំពីការស្រវឹងក្នុងរាងកាយដែលបរិបូណ៌ មានះដែល

កើតឡើងដោយអំណាចនៃសេចក្ដីស្រវឹងថា រាងកាយសត្វទាំងឡាយដ៏សេស(វៀរយើងហើយ) មានទោសច្រើន តែសរីរៈរបស់យើងមិនមានទោស សូម្បីត្រឹមតែប៉ុនសសៃសក់ ឈ្មោះថា បារិបូរិមទោស្រវឹងព្រោះមានរាងកាយបរិបូណ៌ ។

ព្រះមានព្រះភាគត្រាស់មានៈ ការប្រកាន់ខ្លួនដែលប្រព្រឹត្តទៅដោយវត្ថុ (សវត្ថុក) ដោយប្រការមានប្រមាណប៉ុណ្ណេះហើយ ។ ឥឡូវនេះ កាលនឹងទ្រង់សំដែងមានៈមិនមានវត្ថុ(អវត្ថុក)ដែលកំពុងកើតឡើងនោះឯង ទើបត្រាស់ពាក្យជាដើមថា **តត្ថ ភតមោមនោ** ក្នុងពាក្យទាំងនោះ ការស្រវឹងតើដូចម្ដេច ? ពាក្យនោះមានន័យងាយស្រួលទាំងអស់ ។

ប៉ុន្តែ ព្រះធម៌មិនបានសំដែងឱ្យយើងសង្កេត រំពៃចាំចាប់កំហុស អ្នកដទៃនោះទេ ព្រះធម៌គ្រាន់តែចង្អុលបង្ហាញប្រាប់ថា លក្ខណៈបែបនេះ គឺជាអាការនៃសេចក្ដីស្រវឹងតែប៉ុណ្ណោះ ។ ដូច្នេះ គប្បីពិចារណាថា ក្នុងជីវិតប្រចាំថ្ងៃនេះ អាត្មាអញកំពុងមានសេចក្ដីស្រវឹងបែបនេះឬទេ ?

# អធិប្បាយពាក្យថា ឧបធិ

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ឧបធិជាហេតុ ជាបច្ច័យនៃសេចក្តីទុក្ខ ទុក្ខជាភ័យធំរបស់លោកនោះ ត្រង់ពាក្យថា ទុក្ខ គឺទុក្ខព្រោះកំណើត ទុក្ខព្រោះសេចក្តីចាស់ ទុក្ខព្រោះជម្ងឺ ទុក្ខព្រោះសេចក្តីស្លាប់ ទុក្ខព្រោះសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំ ទុក្ខក្នុងកំណើតនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងកំណើតបេត្តវិស័យ ទុក្ខក្នុងកំណើតមនុស្ស ទុក្ខមានការចុះកាន់គភ៌ជាមូល ទុក្ខមានការឋិតនៅក្នុងគភ៌ជាមូល ទុក្ខមានកិរិយាចេញចាកគភ៌ជាមូល ទុក្ខជាបំណងរបស់សត្វដែលកើតហើយ ទុក្ខទាក់ទងដោយបុគ្គលដទៃនៃសត្វដែលកើតហើយ ទុក្ខកើតព្រោះព្យាយាមរបស់ខ្លួន ទុក្ខកើតព្រោះព្យាយាមរបស់បុគ្គលដទៃ ទុក្ខគឺ ទុក្ខវេទនា (ប្រព្រឹត្តទៅក្នុងកាយនិងចិត្ត) ទុក្ខព្រោះសង្ខារ ទុក្ខព្រោះការផ្លាស់ប្តូរ រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគស្លឹកត្រចៀក

រោគមាត់ រោគធ្មេញ ក្អក ហឺត ឫសដូងច្រមុះ ក្ដៅក្រហាយ ស្ពាំងស្គម រោគផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុះរាគ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគក្នុងទីខ្វារដោយ ក្រចក កមរលាយ ប្រមាត់ក្រហម ទឹកនោមផ្អែម ឫសដូងដុះ រលកកែវ ឫសដូងបាត អាពាធកើតព្រោះប្រមាត់ អាពាធកើត អំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីការប្រជុំ (ខ្យល់ ប្រមាត់ ស្លេស្ម) អាពាធកើតអំពីការផ្លាស់ប្ដូររដូវ អាពាធកើត អំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីព្យាយាម (មានការ សំឡាប់នឹងចងជាដើម) អាពាធកើតអំពីផលកម្ម ត្រជាក់ ក្ដៅ សេចក្ដីឃ្លាន សេចក្ដីស្រេក ឧច្ចារៈ បស្សាវៈ ទុក្ខកើតអំពីសម្ផស្ស របស់របោម មូស ខ្យល់ កំដៅថ្ងៃ និងពស់ ការស្លាប់មាតាជាទុក្ខ ការស្លាប់បិតាជាទុក្ខ ការស្លាប់បងប្អូន ប្រុសជាទុក្ខ ការស្លាប់បងប្អូន ស្រីជាទុក្ខ ការស្លាប់កូនប្រុសជាទុក្ខ ការស្លាប់កូនស្រីជាទុក្ខ ការព្រាត់ ប្រាសញាតិជាទុក្ខ ការវិនាសភោគៈ ជាទុក្ខ វិនាសគឺរោគជាទុក្ខ វិនាសសីលជាទុក្ខ វិនាសទិដ្ឋិជាទុក្ខ ការកើតឡើងនៃធម៌ទាំងឡាយ

ណា រមែងប្រាកដក្នុងខាងដើម ការរលត់ទៅ(នៃធម៌ទាំងឡាយនោះ) រមែងប្រាកដដោយការវិនាស វិបាកអាស្រ័យកម្ម កម្មអាស្រ័យវិបាក រូបអាស្រ័យនាម នាមអាស្រ័យរូប ត្រូវជាតិទៅតាមហើយ ត្រូវជរាផ្តេកផ្តិតហើយ ត្រូវព្យាធិគ្របសង្កត់ហើយ ត្រូវមរណៈកំចាត់ហើយ តាំងនៅស៊ប់ ក្នុងសេចក្តីទុក្ខ ឥតមានទីពឹង ឥតមានទីជ្រក ឥតមានទីរឭក ឥតមានទីសង្ឃឹមនេះហៅថា ទុក្ខ ។ ទុក្ខជាភ័យធំ ជាគ្រឿងបៀតបៀន ជាគ្រឿងគាប ជាគ្រឿងឧបទ្រព ជាឧបសគ្គ របស់លោកនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ទុក្ខជាភ័យធំរបស់លោកនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា សេចក្តីទុក្ខ(ទាំងនោះ) ផ្តើមកើតឡើងព្រោះឧបធិជានិទាន ។

ត្រង់ពាក្យថា ឧបធិ បានដល់ឧបធិ ១០ គឺ តណ្ហូបធិ ទិដ្ឋូបធិ កិលេសូបធិ កម្មូបធិ ទុច្ចរិតូបធិ អាហារូបធិ បដិឃូបធិ ឧបាទិន្នធាតុ ៤ ជាឧបធិ អាយតនៈខាងក្នុង ៦ ជាឧបធិ វិញ្ញាណកាយ ៦ ជាឧបធិ សូម្បីទុក្ខទាំងអស់ ឈ្មោះថា ឧបធិដោយសេចក្តីថា ជាទុក្ខ, ទាំងនេះលោកហៅថា ឧបធិ ១០ ។

ពាក្យថា ទុក្ខ បានដល់ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ។ ការត្រូវព្យាធិគ្របសង្កត់ ការត្រូវមរណៈកំចាត់បង់ ការតាំងនៅក្នុងទុក្ខ ការឥតទីពំនាក់ ការឥតមានទីជ្រកកោន ការឥតទីពឹង ការឥតទីពុំនឹងទាំងនេះ ហៅថាទុក្ខ ។ ទុក្ខទាំងនេះ មាន កើតមាន ផ្ដើមកើត កើតឡើង លូតលាស់ ដុះដាល ព្រោះឧបធិជានិទាន ព្រោះឧបធិជាហេតុ ព្រោះឧបធិជាបច្ច័យ ព្រោះឧបធិជាការណ៍ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីទុក្ខ(ទាំងនោះ)ផ្ដើមកើតឡើង ព្រោះឧបធិជានិទាន ។

ពាក្យថា សេចក្ដីទុក្ខទាំងឡាយណាមួយជា ច្រើនប្រការក្នុងលោក ត្រង់ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសល់ ពាក្យថា ណាមួយនុ៎ះ ជាពាក្យប្រមូល ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ជាច្រើនប្រការ គឺទុក្ខទាំង-ឡាយផ្សេងៗជាច្រើន មានប្រការផ្សេង ៗ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការក្នុងលោក ។

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា (ម្នាលមេត្តគូ) អ្នកសួរហេតុជាដែនផ្ដើម កើតនៃសេចក្ដីទុក្ខនឹងតថាគត តថាគតដឹងយ៉ាងណា នឹងប្រាប់ហេតុជា ដែនផ្ដើមកើតនៃសេចក្ដីទុក្ខនោះ ដល់អ្នកយ៉ាងនោះ សេចក្ដីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការក្នុងលោក សេចក្ដីទុក្ខ (ទាំងនោះ) ផ្ដើមកើតឡើង ព្រោះឧបធិជានិទាន ។ បុគ្គលណាមិនចេះ តែងធ្វើឧបធិឱ្យកើតឡើង បុគ្គលល្ងង់ខ្លៅនោះ រមែងបានទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ ជាអ្នកពិចារណាឃើញនូវជាតិជាដែន ផ្ដើមកើតនៃទុក្ខ មិនគប្បីធ្វើនូវឧបធិឡើយ ។

# អភិណ្ហប្បច្ចវេក្ខណធម៌

១ **ជរាធម្មោម្ហិ ជរំ អនតីតោ** ៖ អាត្មាអញមានការចាស់ជរាជាធម្មតា នឹងកន្លងការចាស់ជរាទៅពុំបានឡើយ ។

២ **ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ** ៖ អាត្មាអញមានការឈឺថ្កាត់ជាធម្មតា នឹងកន្លងការឈឺថ្កាត់ទៅពុំបានឡើយ ។

៣ **មរណធម្មោម្ហិ មរណំ អនតីតោ** : អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា នឹងកន្លងសេចក្តីស្លាប់ទៅពុំបានឡើយ ។

៤ **សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ** : អាត្មាអញគង់តែព្រាត់ប្រាស និរាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ពេញចិត្តទាំងអស់ពុំខាន ។

៥ **កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ** : អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឱ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីអាស្រ័យ អាត្មាអញនឹងធ្វើនូវកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងជាអ្នកទទួលយកនូវផលនៃកម្មនោះពុំខាន ។